ធនាគារជាតិ នៃ កម្ពុជា
ប្រាក់រៀល. ស្ថិរភាព. អភិវឌ្ឍន៍.

អង្គការសហប្រជាជាតិ
ប្រទេសកម្ពុជា

*ថ្ងៃព្រហស្បតិ៍ ១០ រោច ខែបុស្ស ឆ្នាំរោង ឆស័ក ព.ស.២៥៦៨*
*រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥*

# សេចក្តីថ្លែងការណ៍រួម
# រវាងធនាគារជាតិនៃកម្ពុជា និង អង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា
# ស្តីពី
# បច្ចុប្បន្នភាពនៃដំណើរការពិគ្រោះយោបល់ជាមួយពហុភាគីពាក់ព័ន្ធ ស្តីពី មីក្រូហិរញ្ញវត្ថុនៅកម្ពុជា

កាលពីថ្ងៃទី២៣ ខែមករា ឆ្នាំ២០២៥ ធនាគារជាតិនៃកម្ពុជា និងអង្គការសហប្រជាជាតិប្រចាំនៅកម្ពុជា បានសហការរៀបចំសម្របសម្រួលកិច្ចសន្ទនាកម្រិតខ្ពស់រវាងពហុភាគីពាក់ព័ន្ធលើកទី២ ស្តីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា ដើម្បីតាមដានវឌ្ឍនភាពសកម្មភាពអាទិភាពចំនួន២២ ដែលត្រូវបានអនុម័តក្នុងកិច្ចសន្ទនាកម្រិតខ្ពស់រវាងពហុភាគីពាក់ព័ន្ធលើកទី១ កាលពីថ្ងៃទី១២ ខែកក្កដា ឆ្នាំ២០២៤ ក្នុងដំណើរការពិគ្រោះយោបល់ជាមួយពហុភាគីពាក់ព័ន្ធ ស្តីពីមីក្រូហិរញ្ញវត្ថុនៅកម្ពុជា។

ដើម្បីឆ្លើយតបនឹងការព្រួយបារម្ភចំពោះកំណើនយ៉ាងឆាប់រហ័សនៃវិស័យមីក្រូហិរញ្ញវត្ថុនៅកម្ពុជា និងភាពប្រទាក់ក្រឡាគ្នាជាមួយបញ្ហាប្រឈមផ្សេងទៀត ដូចជាការជំពាក់បំណុលលើសលប់ ជាដើម ការផ្តួចផ្តើមឱ្យមានដំណើរការពិគ្រោះយោបល់បានចាប់ផ្តើមកាលពីខែវិច្ឆិកា ឆ្នាំ២០២៣ ក្នុងគោលបំណងសម្របសម្រួលឱ្យមានការចូលរួមពិភាក្សាពីភាគីពាក់ព័ន្ធក្នុងន័យស្ថាបនា បង្កើតឱ្យមានការយល់ដឹងរួមគ្នាអំពីបញ្ហាប្រឈមនានា និងកំណត់សកម្មភាពអាទិភាព និងការប្តេជ្ញាចិត្តជាក់លាក់ ដែលអាចជួយគាំទ្រដល់ភាគីពាក់ព័ន្ធទាំងអស់ ក្នុងការដោះស្រាយបញ្ហាប្រឈម និងចាប់យកកាលានុវត្តភាពក្នុងការពង្រឹងវិស័យធនាគារនិងហិរញ្ញវត្ថុ។ កិច្ចសន្ទនាតាមក្រុមនីមួយៗ និងកិច្ចប្រជុំបច្ចេកទេសជាមួយពហុភាគីពាក់ព័ន្ធត្រូវបានរៀបចំឡើងជាបន្តបន្ទាប់ ដោយមានការចូលរួមពិគ្រោះយោបល់ពីតំណាងក្រុម និងស្ថាប័នចំនួនជាង ១០០ ផ្សេងគ្នា រួមមាន៖ តំណាងមកពីរាជរដ្ឋាភិបាល និយ័តករ ស្ថាប័ននិងសមាគមវិជ្ជាជីវៈធនាគារនិងហិរញ្ញវត្ថុ វិនិយោគិន សង្គមស៊ីវិល អង្គការមិនមែនរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ ព្រមទាំងទីភ្នាក់ងារអង្គការសហប្រជាជាតិ និងស្ថាប័នហិរញ្ញវត្ថុអន្តរជាតិ។

## វឌ្ឍនភាពការងារ៖

ក្នុងចំណោមសកម្មភាពអាទិភាពចំនួន២២ សកម្មភាពអាទិភាពចំនួន៤ ត្រូវបានអនុវត្តបានទាំងស្រុង សកម្មភាពអាទិភាពចំនួន១៥ កំពុងត្រូវបានអនុវត្ត និងសកម្មភាពអាទិភាពចំនួន៣ កំពុងត្រូវបានចាប់ផ្តើមអនុវត្ត។ ចំនុចសំខាន់ៗពាក់ព័ន្ធនឹងការអនុវត្តសកម្មភាពអាទិភាពមានដូចខាងក្រោម៖

- **ការពង្រឹងការផ្តល់ឥណទានប្រកបដោយទំនួលខុសត្រូវ៖** ការលើកកម្ពស់ស្តង់ដាក្នុងការផ្តល់ឥណទានប្រកបដោយការទទួលខុសត្រូវ មានវឌ្ឍនភាពគួរឱ្យកត់សម្គាល់ ដោយរួមបញ្ចូលទាំងការពង្រឹងការអនុវត្តក្រមប្រតិបត្តិ និងការប្រើប្រាស់ឧបករណ៍វាយតម្លៃ

និងតាមដានសុខដុមនីយកម្មនៃកិច្ចការពារអតិថិជន ដោយមានគ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុចំនួន ៣០ គ្រោងនឹងចូលរួមក្នុងការវាយតម្លៃដោយភាគីទីបី នាពេលខាងមុខ។ គោលការណ៍ណែនាំស្ដីពីវិធានក្នុងការផ្ដល់ឥណទានត្រូវបានពង្រឹង ដោយមានការហាមឃាត់ការប្រើប្រាស់បណ្ណកម្មសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ជាទ្រព្យធានា និងការទប់ស្កាត់ការលក់ដោយបង្ខំនូវបណ្ណកម្មសិទ្ធិទាំងនោះ។ បច្ចុប្បន្ន គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុអាចពិនិត្យមើលតាមប្រព័ន្ធអនឡាញនូវព័ត៌មានលើបណ្ណកម្មសិទ្ធិដែលត្រូវបានចុះបញ្ជីជាបណ្ណកម្មសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច និងដីដែលជាកម្មសិទ្ធិរដ្ឋ ដែលត្រូវបានហាមឃាត់ដោយច្បាប់ក្នុងការប្រើប្រាស់ជាទ្រព្យធានា។

- **ការធ្វើឱ្យប្រសើរឡើងនូវគោលការណ៍លើកទឹកចិត្តរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ៖** សូចនាករសមិទ្ធកម្មគន្លឹះរបស់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុសម្រាប់វាយតម្លៃបុគ្គលិកកំពុងត្រូវបានពិនិត្យ និងកែសម្រួលឱ្យស្របតាមគោលការណ៍ដែលមានចែងក្នុងក្រមប្រតិបត្តិសម្រាប់គ្រឹះស្ថានធនាគារនិងហិរញ្ញវត្ថុ និងគោលការណ៍ណែនាំស្ដីពីវិធានក្នុងការផ្ដល់ឥណទានប្រកបដោយការទទួលខុសត្រូវ និងគោលការណ៍ "មិនធ្វើឱ្យមានការលំបាក"។
- **ការការពារផ្លូវច្បាប់៖** សេចក្ដីថ្លែងការណ៍រួមត្រូវបានរៀបចំឡើង ដើម្បីពង្រឹងបទប្បញ្ញត្តិដែលមានស្រាប់សម្រាប់ទប់ស្កាត់ការប្រើប្រាស់មិនត្រឹមត្រូវនូវឯកសារសម្គាល់អត្តសញ្ញាណដូចជា បណ្ណសមធម៌ អត្តសញ្ញាណបណ្ណ និងសៀវភៅគ្រួសារ ធ្វើជាទ្រព្យធានាសម្រាប់ឥណទានគ្រប់រូបភាព។
- **យន្តការការពារអ្នកប្រើប្រាស់ និងដោះស្រាយបណ្ដឹង៖** គំនិតផ្ដួចផ្ដើមដើម្បីពង្រឹងកិច្ចការពារអ្នកប្រើប្រាស់ និងពង្រឹងយន្តការដោះស្រាយបណ្ដឹងកំពុងត្រូវបានអនុវត្ត។ ជាក់ស្ដែង មជ្ឈមណ្ឌលអតិថិជនដែលប្រើប្រាស់សេវាហិរញ្ញវត្ថុ កំពុងត្រូវបានរៀបចំបង្កើតឡើងដោយសមាគមធនាគារនៅកម្ពុជា និង សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងការសិក្សាលើជម្រើសក្នុងការបង្កើតយន្តការប្រឹក្សានិងសន្ទានកម្មបំណុលឯករាជ្យ បន្ថែមពីលើយន្តការដែលកំពុងត្រូវបានអនុវត្តស្រាប់។ បន្ថែមពីនេះ យុទ្ធនាការនិងកម្មវិធីលើកកម្ពស់ចំណេះដឹងផ្នែកហិរញ្ញវត្ថុ និងការបង្កើនសិទ្ធិរបស់អតិថិជន ក៏ត្រូវបានអនុវត្តដើម្បីផ្ដល់ព័ត៌មានដល់អតិថិជន ជាពិសេសអតិថិជនដែលកំពុងជួបភាពតានតឹងពាក់ព័ន្ធនឹងបំណុល។
- **ប្រព័ន្ធអេក្ស៊ីទិន្នន័យ និងការរៀបចំឥណទានឡើងវិញ៖** កិច្ចខិតខំប្រឹងប្រែងដើម្បីបង្កើតប្រព័ន្ធចែករំលែក វិភាគ និងរាយការណ៍ទិន្នន័យសម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ និងវិស័យហិរញ្ញវត្ថុមិនមែនធនាគារ កំពុងត្រូវបានពិនិត្យ។ វិធានការពាក់ព័ន្ធនឹងការរៀបចំឥណទានឡើងវិញត្រូវបានដាក់ឱ្យអនុវត្តជាបន្តបន្ទាប់ ដោយផ្ដល់អាទិភាពដល់អតិថិជនដែលជួបប្រទះការលំបាកផ្នែកហិរញ្ញវត្ថុ រួមទាំងក្រុមងាយរងគ្រោះ និងក្រុមជនជាតិដើមភាគតិច។ សមាគមមីក្រូហិរញ្ញវត្ថុកម្ពុជា និងសមាគមធនាគារនៅកម្ពុជា បានរៀបចំសេចក្ដីព្រាងនិយមន័យប្រតិបត្តិការមីក្រូហិរញ្ញវត្ថុ សម្រាប់វិស័យធនាគារនិងហិរញ្ញវត្ថុ នឹងត្រូវដាក់ជូន ធនាគារជាតិនៃកម្ពុជា ដើម្បីពិនិត្យ និងប្រមូលធាតុចូលពីភាគីពាក់ព័ន្ធ។

- **នវានុវត្តន៍សេវាធានារ៉ាប់រង៖** កម្មវិធីសាកល្បងពាក់ព័ន្ធនឹងការធានារ៉ាប់រងដំណាំក្រោមសហគមន៍កសិកម្មទំនើបត្រូវបានចាប់ផ្ដើម ដោយមានការគាំទ្រពីវិស័យឯកជន។ ការសិក្សាបន្ថែមត្រូវបានរៀបចំឡើង ដើម្បីស្វែងរកគំរូធានារ៉ាប់រងដ៏ល្អប្រសើរសម្រាប់ពង្រីកវិសាលភាពនៃគំនិតផ្ដួចផ្ដើមនេះ។ បន្ថែមពីនេះ ការពង្រឹងការសម្របសម្រួល និងការគាំទ្រផ្នែកហិរញ្ញវត្ថុជាកត្តាចាំបាច់ដើម្បីផ្ដល់សិទ្ធិដល់សហគមន៍កសិកម្មទំនើប សម្រាប់លទ្ធភាពចូលទីផ្សារ និងឱកាសទទួលបានឥណទានសម្រាប់សហគមន៍ជនជាតិដើមភាគតិចជាមួយនឹងបណ្ណកម្មសិទ្ធិដីធ្លីរបស់សហគមន៍ជនជាតិដើមភាគតិច ។

វឌ្ឍនភាពនៃការអនុវត្តសកម្មភាពអាទិភាពនឹងត្រូវបានបន្តការពិនិត្យ និងតាមដាន ហើយកិច្ចសន្ទនាកម្រិតខ្ពស់ជាមួយពហុភាគីពាក់ព័ន្ធបន្ទាប់ គ្រោងនឹងរៀបចំឡើងក្នុងខែសីហា ឆ្នាំ២០២៥។ តំណាងភាគីពាក់ព័ន្ធដែលបានចូលរួមក្នុងកិច្ចសន្ទនា បានបន្តការប្ដេជ្ញាចិត្ត ក្នុងការបង្កើនភាពត្រឹមត្រូវ និងតម្លាភាពនៅក្នុងប្រព័ន្ធអេកូឡូស៊ីធនាគារនិងហិរញ្ញវត្ថុ តាមរយៈការលើកកម្ពស់ការអនុវត្តប្រកបដោយការទទួលខុសត្រូវ និងបរិយាបន្ន ដែលនឹងផ្ដល់សិទ្ធិបន្ថែមជូនប្រជាជនកម្ពុជា ជាពិសេស ក្រុមងាយរងគ្រោះស្របពេលជាមួយគ្នាដែលកម្ពុជាកំពុងអភិវឌ្ឍប្រកបដោយចីរភាព និងរួមចំណែកដល់ស្ថិរភាពសេដ្ឋកិច្ច។

តំណាងភាគីពាក់ព័ន្ធបានបញ្ជាក់ឡើងវិញអំពីការប្ដេជ្ញាចិត្តរួមគ្នា ដើម្បីសម្រេចគោលដៅខាងលើ និងដោះស្រាយបញ្ហាប្រឈមរួមគ្នា តាមរយៈកិច្ចសហប្រតិបត្តិការជិតស្និទ្ធជាមួយគ្រប់ភាគីពាក់ព័ន្ធ។


**ទំនាក់ទំនង ៖**

១. អង្គភាពទំនាក់ទំនង ធនាគារជាតិនៃកម្ពុជា
ទូរស័ព្ទ ៖ (៨៥៥) ២៣ ៩៨០ ១៩៦
អ៊ីម៉ែល ៖ nbccommunication@nbc.gov.kh

**បណ្ដាញសារព័ត៌មានផ្លូវការរបស់ធនាគារជាតិនៃកម្ពុជា ៖**
www.nbc.gov.kh , www.facebook.com/nationalbankofcambodiaofficial , www.twitter.com/nbccambodia , www.instagram.com/nationalbankofcambodia , www.linkedin.com/company/national-bank-of-cambodia , www.youtube.com/channel/UC3GoCm_QGSSLjXZXvbcATfA

២. កញ្ញា កែវ ស្រីស្រស់ មន្ត្រីទំនាក់ទំនង និងស្វែងរកការគាំទ្រ
នៃ**ការិយាល័យអ្នកសម្របសម្រួលអង្គការសហប្រជាជាតិប្រចាំកម្ពុជា**
ទូរស័ព្ទ ៖ (៨៥៥) ១១ ៨៨ ៥៧ ៦៦
អ៊ីម៉ែល ៖ sreysros.keo@un.org